# ការធ្វើឲប្រែប្រួល នៃអំណាច ?

របបនយោបាយទាំងឡាយ សព្វថ្ងៃ រមែងប្រទល់នឹងបរិស្ថានថ្មី។ ទោះបីជា កន្លែងពិសេសមួយ ដែលប្រជាធិបតី កាន់យកសិទ្ធិហួសប្រមាណថា ខ្លួនឯងជា អំណាចប្រព្រឹត្តទៅខុសផ្លែកពីអំណាចដទៃ តែការសំដៅទៅរកកន្លែងតែមួយ រវាងលទ្ធិនេះ និង របបផ្តាច់ការ គឺបញ្ហារួម នៅចំពោះមុខការវាត នៃ តក្កសេដ្ឋកិច្ច និង វឌ្ឍនភាព នៃទំនិញ និង ភាពស្មុកស្មាញ នៃសេវាកម្មហិរញ្ញវត្ថុនៅលើលោកនេះ។ គ្រប់អំណាច ត្រូវតែប្រឈមមុខនឹង អប្បជនាធិបតេយ្យបនីយកម្ម ដែលប្រមូលផ្តុំ អំណាចរូបិយវត្ថុ និង និមិត្តរូប នៅក្នុងដៃរបស់ជនមួយក្រុមតូច។ ភាពប្រែប្រួល កើតឡើង នៅក្នុងវណ្ណៈថ្មីនេះ ដែលចែករំលែកប្រយោជន៍គ្នានៅក្នុងមជ្ឈដ្ឋានរួមរមែងធ្វើឲប្រែប្រួលអំណាច។ ជាជម្មតា នៅចំពោះបញ្ហានេះ របបផ្តាច់ការ មានប្រតិកម្មតាមការពង្រឹងអំណាច និង ការរឹតត្បិតសេរីភាព ដោយប្រើច្បាប់ សំរាប់ការពារអំណាចខ្លួន។ ចំណែក ប្រទេសប្រជាធិបតេយ្យសេរី ធ្វើប្រតិភូកម្មអំណាច នៃការឃ្លាំមើលទៅឲក្រុមហ៊ុនធំពីរបី ដើម្បីការពារផលប្រយោជន៍អាយុជីវិត នៃសេដ្ឋកិច្ចជាតិ។ តែប្រជាជនងាយរងគ្រោះរស់នៅក្នុងបញ្ហាចិញ្ចឹមជីវិតប្រចាំថ្ងៃលែងមើលឃើញភាពខុសគ្នារវាង អំណាចផ្តាច់ការ និង ប្រជាធិបតី ដែលនាំឲរបបផ្តាច់ការ បញ្ជោតថា ខ្លួនអាចធានា ឲមានស្ថិរភាព សង្គម និង នយោបាយ ជាងប្រជាធិបតី។ តែស្ថិរភាពនេះ វាគ្មាននីតិរដ្ឋ ខុសពីប្រជាធិបតី ឈរលើនីតិរដ្ឋ៕